អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ សមថកម្មដ្ឋាន

website ៖ www.hoksavann.org

ថ្ងៃទី២១ មិថុនា ២០០៨



អត្ថបទមុន យើងបានអធិប្បាយអំពីវិបស្សនាកម្ម-ដ្ឋាន ឥឡូវនេះសូមអធិប្បាយអំពីសមថកម្មដ្ឋាន ព្រោះកម្មដ្ឋានទាំង២ នេះមានទំនាក់ទំនងគ្នា បន្ទាប់មកនឹងអធិប្បាយអំពីវិបស្សនាកម្មដ្ឋានជាបន្តទៅទៀត ។ សមថកម្មដ្ឋានស្មើនឹងពាក្យសមាធិកម្មដ្ឋាន ។ សមថកម្មដ្ឋានចែកជាពីរបទគឺ សមថៈមួយបទ កម្មដ្ឋានមួយបទ ។ កម្មដ្ឋានប្រែថា ហេតុជាទីតាំងនៃបរិកម្ម ភាវនា បានដល់អារម្មណ៍ដែលបុគ្គលយកមកសំឡឹង យកមកគិតពិចារណា ។ សមថៈប្រែថា ចិត្តស្ងប់ គឺស្ងប់នូវនីវរណធម៌ទាំង៥គឺ កាមឆន្ទៈ ចិត្តនឹកទៅរកកាម, ព្យាបាទៈ ចិត្តនឹកគិតព្យាបាទ, ថីនមិទ្ធៈ ចិត្តងោកងុយ, ឧទ្ធច្ចកុក្កុច្ចៈ ចិត្តរាយមាយ និងវិ-ចិកិច្ឆា ចិត្តសង្ស័យ ។ ចិត្តរបស់មនុស្សបុថុជ្ជន ដែលមិនទាន់កើតសមាធិចិត្ត តែងមាននីវរណធម៌ទាំង៥នេះជានិច្ច ។ នីវរណធម៌ប្រែថា ធម៌រារាំងផ្លូវចិត្ត ធ្វើឲ្យចិត្តសៅហ្មង មិនឲ្យចិត្តបរិសុទ្ធ ។ នៅពេលដែលបុគ្គលយកកម្មដ្ឋានណាមួយមកភាវនារហូតដល់ចិត្តស្ងប់នូវនីវរណធម៌នោះ លោកហៅថា សមថៈ ។ រួមពាក្យទាំងពីរបទ សមថកម្មដ្ឋានប្រែថា អារម្មណ៍ដែលបុគ្គលយកមកភាវនា ដើម្បីឲ្យកើតសមថចិត្ត គឺចិត្តស្ងប់ ។

សមាធិកម្មដ្ឋានក៏ចែកជាពីរបទគឺ សមាធិមួយបទ និងកម្មដ្ឋានមួយបទ ។ សមាធិ មានបទវិគ្គហៈថា កុសលចិត្តេកគ្គតាសមាធិប្រែថា ភាពរបស់ចិត្ត និងចេតសិកជាកុសល ដែលដំកល់ស្មើល្អក្នុងអារម្មណ៍តែមួយ ហៅថាសមាធិ ។

ចំណែកពាក្យថា កម្មដ្ឋានមាន សេចក្ដីដូចពោលមកហើយ ។ រួមពាក្យទាំងពីរបទ សមាធិកម្មដ្ឋានប្រែថា អារម្មណ៍ដែលបុគ្គលយកមកភាវនា ដើម្បីឲ្យចិត្តមានអារម្មណ៍តែមួយ ។ ចិត្តដែលមានអារម្មណ៍តែមួយ ។ ចិត្តដែលមានអារម្មណ៍តែមួយ លុះត្រាតែចិត្តស្ងប់នូវនីវរណធម៌ ។ ដូច្នេះសមថកម្មដ្ឋាន និងសមាធិកម្មដ្ឋាន ជាពាក្យអាចប្រើផ្លាស់ប្ដូរគ្នាបាន មានន័យដូចគ្នា ។ កម្មដ្ឋានជាហេតុ, សមថចិត្ត និងសមាធិចិត្ត ជាផល ។ ពាក្យថា បរិកម្មភាវនាបានន័យថា យកកម្មដ្ឋានណាមួយមករំពឹងគិតពិចារណា ។

សមថកម្មដ្ឋាន ឬសមាធិកម្មដ្ឋាន មាន៤០ជាអារម្មណ៍ ដែលបុគ្គលយកមករំពឹងគិតពិចារណា ជាអារម្មណ៍របស់ចិត្ត ដើម្បីឲ្យចិត្តកើតសមាធិ ។ សមាធិនេះភាសាបារាំងនិងអង់គ្លេសហៅថា concentration ។ សមថកម្មដ្ឋាន៤០នោះ គឺកសិណ១០, អនុស្សតិ ១០, អសុភ១០, ព្រហ្មវិហារ៤, អរូប៤, ចតុធាតុវវត្ថាន ១, អាហារេបដិកូលសញ្ញា១ ។ បំណងរបស់សមថកម្មដ្ឋានក្នុងបាលីថា ចេតោវិមុត្តិ ប្រែថា ការរួចចាកនីវរណធម៌ដោយអំណាចសមថចិត្ត ឬសមាធិចិត្ត ។

មុននឹងលើកយកកម្មដ្ឋានណាមួយមកចំរើន បើយោលតាមគម្ពីរវិសុទ្ធិមគ្គពោលថា ត្រូវដឹងអារម្មណ៍របស់កម្មដ្ឋាន ដែលមានលក្ខណៈផ្សេងគ្នា៥ប្រភេទគឺ

១- កម្មដ្ឋាន២២គឺ កសិណ១០ អសុភ១០ អានាបានស្សតិ១ កាយគតាសតិ១ កាន់យកបដិភាគនិមិត្តមកជាអារម្មណ៍ ។

២- កម្មដ្ឋាន១២គឺ អនុស្សតិ៨ លើកអានាបានស្សតិ និងកាយគតាសតិចេញ បញ្ចូលអាហារបដិកូលសញ្ញា១ ចតុធាតុវវត្ថាន១ វិញ្ញាណញ្ចាយតនៈ១ នេវសញ្ញានាសញ្ញាយតនៈ១ កាន់យកសភាពធម៌មកជាអារម្មណ៍ ។

៣- កម្មដ្ឋាន២២គឺ កសិណ១០ អសុភ១០ អានាបានស្សតិ១ កាយគតាសតិ១ កាន់យកនិមិត្តមកជាអារម្មណ៍ ។

៤- កម្មដ្ឋាន៦គឺ ព្រហ្មវិហារ៤ អាកាសានញ្ចាយតនៈ១ អាកិញ្ចញ្ញាយតនៈ១ កាន់យកនូវអារម្មណ៍ពោលកំណត់មិនបាន ។

៥- កម្មដ្ឋាន៨គឺ វិបុព្វកអសុភ១ លោហិតកអសុភ១ បុឡុវកអសុភ១ អានាបានស្សតិ១ អាបោកសិណ១ តេជោកសិណ១ វាយោកសិណ១ អាលោកកសិណ១ មុននឹងកើតបដិភាគនិមិត្តអារម្មណ៍ញ័រ ។

ផ្នែកសមថកម្មដ្ឋាន លោកឲ្យចំរើនទៅតាមចរិតរបស់បុគ្គលមួយរូបៗ ប្រៀបដូច ជម្ងឺផ្លូវកាយត្រូវដាក់ថ្នាំឲ្យស្របតាមប្រភេទជម្ងឺ ទើបជម្ងឺបានជាសះ

ស្បើយ ។ ចរិតដោយសង្ខេបមាន៦គឺ ៖

១- រាគចរិត លំនាំរាគៈ គឺច្រើនដោយសេចក្តីតម្រេក ។

២- ទោសចរិត លំនាំទោសៈ គឺច្រើនដោយសេចក្តីប្រទុស្ត ។

៣- មោហចរិត លំនាំមោហៈ គឺច្រើនដោយសេចក្តីវង្វេង ។

៤- សទ្ធាចរិត លំនាំសទ្ធា គឺច្រើនដោយសេចក្តីជឿ ។

៥- ពុទ្ធិចរិត លំនាំប្រាជ្ញា គឺច្រើនដោយសេចក្តីចេះដឹង ។

៦- វិតក្កចរិត លំនាំវិតក្កៈ គឺច្រើនដោយសេចក្តីត្រិះរិះ ។

ចរិតរបស់បុគ្គលមួយរូបៗ មានចរិតច្រើនលាយឡំគ្នា ប៉ុន្តែលោកឲ្យពិនិត្យមើលចរិតណាមួយកើតឡើងខ្លាំងជាងគេ ដូចជាជម្ងឺផ្លូវកាយកើតឡើង មានជម្ងឺចុកពោះផង ឈឺក្បាលផង គ្រុនផង គេត្រូវដាក់ថ្នាំចំពោះជម្ងឺណា ដែលឈឺខ្លាំងជាងគេជាមុន ។ ដើម្បីឲ្យដឹងចរិតបែបណាមួយផុះផុល កើតឡើងខ្លាំងក្នុងសន្តាន គេត្រូវពិនិត្យសង្កេតមើលឥរិយាបថ ស្នាដៃធ្វើការងារ, កិរិយាបរិភោគភោជន, កិរិយាក្រឡេកឃើញរូបជាដើម និងសង្កេតមើលធម៌ដែល ប្រព្រឹត្តនៅក្នុងសន្តាន ។

តទៅនេះ សូមពិនិត្យមើលកម្មដ្ឋានណាដែលសមគួរដល់បុគ្គលមានចរិតបែបណា ត្រូវលើកយកមកចំរើន ។ កម្មដ្ឋាន១១ គឺអសុភ១០ កាយគតាសតិ១ សមគួរដល់បុគ្គលជារាគចរិត; កម្មដ្ឋាន៨គឺ ព្រហ្មវិហារ៤ វណ្ណកសិណ៤ គឺនីលកសិណ១ បីតកសិណ១ លោហិតកសិណ១ ឱទាតកសិណ១ សមគួរដល់បុគ្គលជាទោសចរិត; អានាបានស្សតិតែមួយ សមគួរដល់បុគ្គលជាមោហចរិត និងវិតក្កចរិត; អនុស្សតិ៦ខាងដើមគឺ ពុទ្ធានុស្សតិ១ ធម្មានុស្សតិ១ សង្ឃានុស្សតិ១ សីលានុស្សតិ១ ចាគានុស្សតិ១ ទេវតានុស្សតិ១ សមគួរដល់បុគ្គលជាសទ្ធាចរិត; កម្មដ្ឋាន៤គឺ មរណានុស្សតិ១ ឧបសមានុស្សតិ១ ចតុធាតុវវត្ថាន១ អាហារេបដិកូលសញ្ញា១ សមគួរដល់បុគ្គលជាពុទ្ធិចរិត; កម្មដ្ឋានសល់ពីនោះ១០គឺ បឋវីកសិណ១ អាបោកសិណ១ តេជោកសិណ១ វាយោកសិណ១ អាកាសកសិណ១ អាលោកកសិណ១ និងអរូប្ប៤ សមគួរដល់បុគ្គលគ្រប់ចរិតទាំងអស់។

ការរៀបរាប់មកនេះ ហាក់ដូចជាពោលអំពីមាតិកាធម៌ច្រើនពេក ដែលធ្វើឲ្យអ្នកអានធុញទ្រាន់ ប៉ុន្តែជាការចាំបាច់ត្រូវតែពោលនូវគោលធម៌ទាំងនេះ មុននឹងលើកយកមកអធិប្បាយ ជាពិសេសតទៅនេះ សូមពន្យល់អំពីវិធីចំរើនកម្មដ្ឋានខ្លះ ដោយយោលទៅតាមការស្រាវជ្រាវក្នុងព្រះពុទ្ធដីកា និងអដ្ឋកថា ព្រមទាំ

ងចំណោះខាងការពិសោធខ្លួនឯងខ្លះផង ។

## របៀបចំរើនអានាបានស្សតិ

អានាបានស្សតិប្រែថា ការកំណត់ដង្ហើមចេញចូលត្រង់ចុងច្រមុះ ។ តាមសៀវភៅសមាធិនិទ្ទេសសង្ខេបរបស់ព្រះគ្រូអ៊ុច-រស ឲ្យចំរើនដោយរាប់ខ្យល់ជាគូៗ ថាមួយៗពីរៗរហូតដល់ប្រាំ ហើយបន្តរហូតដល់ដប់ ។ ការរាប់របៀបគណិតសាស្ត្រនេះពុំត្រឹមត្រូវឡើយ ព្រោះមិនស៊ីសង្វាក់នឹងដំណើរខ្យល់ដកចេញចូល មិនអាចហៅថា ការចំរើនអានាបាខ្យល់ដង្ហើមចេញចូលឡើយ ។ ដើម្បីយល់របៀបចំរើនអានាបានេះ សូមយល់អត្ថន័យ៤ប្រការគឺ ១- ផុស្សនា គឺត្រូវដឹងកន្លែងដែលខ្យល់ប៉ះត្រូវ គឺនៅត្រង់ប្រហោងចុងច្រមុះ, ២- អនុពន្ធនា គឺចងក្រៀកចិត្តទៅត្រង់កន្លែងដែលខ្យល់ប៉ះត្រូវ, ៣- គណនា ត្រង់គណនានេះហើយដែលច្រឡំថារាប់ ប៉ុន្តែនៅក្នុងគិរីមានន្ទសូត្រ និងអដ្ឋកថាថា ត្រង់គណនានេះ គឺជានាតិឲ្យកំណត់ដឹង ពុំមែនរាប់ខ្យល់ឡើយ, ៤- ឋបនា ពេលកំណត់ខ្យល់ដង្ហើមចេញចូល ចិត្តស្ងប់ ជាតួអប្បនាចិត្ត ។ សូមបញ្ជាក់ថា ខ្យល់ត្រូវដកចេញចូលតាមធម្មតា មិនត្រូវប្រឹងដកឲ្យញាប់ឬដកតិចៗដើម្បីកំណត់ឡើយ។ តាមបច្ចេកទេសរបស់គ្រូភូមា ឲ្យកំណត់ត្រង់ពោះប៉ោងផត តាមពិតការកំណត់ត្រង់ទ្រូងក្តី ត្រង់ពោះក្តី ពុំអាចដឹងខ្យល់ប៉ះត្រូវដូចនៅត្រង់ចុងច្រមុះឡើយ ។ លោកប្រៀបដូចសត្វគោ ដែលគេលែងឲ្យស៊ីស្មៅនៅកន្លែងផ្សេងៗ លុះវាស្រេកទឹក វានឹងចុះមកផឹកទឹក ម្ចាស់គោចាំចាប់វាត្រង់កំពង់ទឹក ដូចខ្យល់ចេញចូលតាមប្រហោងចុងច្រមុះ មិនត្រូវតាមកំណត់នៅកន្លែងផ្សេងពីនេះទេ ។ ការកំណត់ត្រូវតាំងនាទីដូចជាអ្នកយាមទ្វារ អ្នកណាចេញចូលឲ្យកំណត់ដឹង ។ ខ្យល់មាន៤បែបគឺ ឱឡារិក: ខ្យល់គ្រោតគ្រាតគឺខ្យល់ធម្មតារបស់មនុស្សដែលមិនបានចំរើនអានាបា; សុខុម: ខ្យល់ល្អិត, អតិសុខុម: ខ្យល់ល្អិតក្រៃលែង, អនិច្ចលាតិ ខ្យល់មិនកំរើក នេះជាដំណើរអ្នកចំរើនអានាបាកើតខ្យល់តាមលំដាប់លំដោយ។ និមិត្តដែលកើតឡើងក្នុងខ្យល់ គឺឃើញដូចជាប៉ុយគរប៉ុយកប្បាស ឬឃើញដូចជាពពករសាត់ នេះជាឧគ្គហនិមិត្ត និងបដិភាគនិមិត្តកើតឡើងហើយ ។ ការកំណត់រហូតចិត្តស្ងប់នូវនីវរណធម៌ ជាតួសមថកម្មដ្ឋាន បើការកំណត់ឃើញការកើតរលត់របស់សង្ខារជាត្រៃលក្ខណធម៌ ជាតួវិបស្សនា ។ ពេលក្រោយនឹងលើកយករបៀបចំរើនកម្មដ្ឋានផ្សេងទៀតមកអធិប្បាយ ។ ៚

❑